**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ស្ថានឯកអគ្គរាជទូតកម្ពុជា**
**ប្រចាំសាធារណរដ្ឋកូរ៉េ**

# សេចក្តីជូនដំណឹង
## ស្តីពីការបន្តសេវាផ្តល់លិខិតឆ្លងដែនជូនពលរដ្ឋខ្មែរនៅសា.កូរ៉េ

ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំសាធារណរដ្ឋកូរ៉េ មានកិត្តិយស សូមជម្រាបជូនដំណឹងដល់សាធារណៈជនទាំងអស់ឱ្យបានជ្រាបថា ផ្អែកតាមអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងយោងសេចក្តីជូនដំណឹងរបស់ក្រសួងមហាផ្ទៃ លេខ ០៥២ សជណចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០២៤ ស្ថានទូតបានដាក់ឱ្យដំណើរការសេវាផ្តល់លិខិតឆ្លងដែនធម្មតា ជូនប្រជាពលរដ្ឋ និងពលករកម្ពុជា ដែលកំពុងស្នាក់នៅ និងធ្វើការនៅសា.កូរ៉េ ដើម្បីសម្រួលដល់ការលំបាក និងកាត់បន្ថយថ្លៃចំណាយផ្សេងៗ ដែលក្នុងជំហានដំបូង គិតចាប់ពីថ្ងៃទី ១០ ខែមករា ឆ្នាំ២០២៤ ដល់ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២៤ ដូចមានសេចក្តីជូនដំណឹងរបស់ស្ថានទូត ចុះថ្ងៃទី ០៩ ខែមករា ឆ្នាំ២០២៤។

ក្នុងឱកាសអញ្ជើញមកបំពេញទស្សនៈកិច្ចផ្លូវការរបស់**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា នៅសា.កូរ៉េ ចាប់ពីថ្ងៃទី ១៥ ដល់ថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២៤ **សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី** បានអញ្ជើញជួបសំណេះសំណាលជាមួយបងប្អូនសហគមន៍ខ្មែរនៅសា.កូរ៉េ ដែលក្នុងឱកាសនោះ **សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី** បានប្រកាសឱ្យបន្តការផ្តល់សេវាធ្វើលិខិតឆ្លងដែនជូនពលរដ្ឋខ្មែរ រយៈពេល **០៣ ខែ** បន្តទៀត គិតចាប់ពីថ្ងៃ**ទី ២០ ខែឧសភា ឆ្នាំ២០២៤ ដល់ថ្ងៃទី ២៥ ខែសីហា ឆ្នាំ២០២៤** ដូចមានសេចក្តីជូនដំណឹងរបស់ស្ថានទូតចុះថ្ងៃទី ២០ ខែឧសភា ឆ្នាំ២០២៤។

យោងតាមការវាយតម្លៃទៅលើចំនួននៃការដាក់ពាក្យស្នើសុំធ្វើលិខិតឆ្លងដែន របស់ពលរដ្ឋខ្មែរ នៅមិនទាន់សម្រេចបានទៅតាមចំនួនដែលបានរំពឹងទុកនៅឡើយ ស្របពេលដែលបងប្អូនពលរដ្ឋខ្មែរយើងនៅតែបន្តអញ្ជើញមកដាក់ពាក្យស្នើសុំជាបន្តបន្ទាប់ ដូច្នេះ ស្ថានទូតក៏បានស្នើសុំគោលការណ៍ពីប្រមុខរាជរដ្ឋាភិបាល ដើម្បីបន្តសេវាផ្តល់លិខិតឆ្លងដែននេះ មួយរយៈទៀត។

ក្នុងន័យនេះ ដោយបានទទួលគោលការណ៍សម្រេចដ៏ខ្ពង់ខ្ពស់ពី **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំសា.កូរ៉េ មានសេចក្តីសោមនស្សរីករាយ សូមជម្រាបជូនដំណឹងដល់បងប្អូនប្រជាពលរដ្ឋខ្មែរ ដែលកំពុងរស់នៅ និងធ្វើការនៅសា.កូរ៉េ ជ្រាបថា ស្ថានទូតនឹងបន្តសេវាផ្តល់លិខិតឆ្លងដែនធម្មតានៅសា.កូរ៉េ ចំនួន **៦០ ថ្ងៃទៀត** ដោយគិតចាប់ពីថ្ងៃ**ទី ០៤ ខែកញ្ញា ឆ្នាំ២០២៤ ដល់ថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០២៤ (ចាប់ពីថ្ងៃពុធ ដល់ថ្ងៃអាទិត្យ ជារៀងរាល់សប្តាហ៍)**។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណៈជនទាំងអស់ ជ្រាបជាព័ត៌មាន។

ថ្ងៃសុក្រ ៤ រោច ខែស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស ២៥៦៨

សេអ៊ូល ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២៤

Royal Embassy of Cambodia
14F, Booyoung Taepyeong Building,
55 Sejong Daero, Jung-gu, Seoul 04513

Tel : 82 2 3785 1041
Fax : 82 2 3785 1040
e-mail : camemb.kor@mfaic.gov.kh